

ថ្ងៃនេះ រតនានិងមករាសប្បាយចិត្តខ្លាំងណាស់ ដោយសារវ៉ាកងតូចទើបចាប់ផ្តើម។
ថ្ងៃចូលឆ្នាំប្រពៃណីខ្មែរជិតមកដល់ហើយ ដូចនេះម្នាក់ៗរវល់ណាស់
ព្រោះមានរបស់របរច្រើនត្រូវរៀបចំ។



នៅថ្ងៃចន្ទ រតនានិងមករាបានទៅទិញខោអាវនៅផ្សារជាមួយម្ដាយគាត់។
រតនាស្រឡាញ់រ៉ូបពណ៌ខៀវដ៏ស្រស់ស្អាតមួយ តែពេលនាងលទៅ រ៉ូបនោះបែរជាតូចពេក។
ដូច្នេះនាងក៏សាកលរ៉ូបពណ៌បៃតងវិញ តែវាបែរជាធំពេកទៅវិញ។
ចុងក្រោយនាងក៏សាករ៉ូបពណ៌លឿងមួយដែលត្រូវនឹងខ្លួននាងល្មមតែម្ដង។
ឯមករាវិញបានទិញខោពណ៌ក្រហមនិងអាវយឺតឆ្នូតមួយផងដែរ។



នៅថ្ងៃអង្គារ មានសំឡេងស៊ីប្លេនៅក្រៅផ្ទះរបស់ក្មេងៗ។
ម្តាយរបស់ក្មេងទាំងពីរនិយាយ « ម៉ោះ! ថ្ងៃនេះយើងត្រូវទិញអីវ៉ាន់ច្រើនណាស់ »។
លោកគ្រូសុខកំពុងចាំពួកគេនៅលើរ៉ឺម៉កកង់បី។ សាកទាយមើលនរណាគេជាអ្នកបើករ៉ឺម៉កកង់បី?
គឺយ៉េកនោះឯង!
រតនានិងមករាសប្បាយចិត្តណាស់ដែលបានជួបយ៉េកម្តងទៀត។
លោកគ្រូសុខបានណែនាំយ៉េកឱ្យម្តាយក្មេងទាំងពីរបានស្គាល់។
រតនាសួរ « តើខេទីនៅឯណា? »
យ៉េកក៏ឆ្លើយ « មកពីមនុស្សច្រើនពេក ប្រហែលជិះមិនអស់ទេ ដូច្នេះនាងក៏ចាំនៅផ្ទះទៅ »។



ពេលទៅដល់ផ្សារ ពួកគេបានទិញភ្លើងលំអ ទាននិងធូបជាច្រើន។
យ៉េកសួរ « ទិញរបស់ទាំងនេះសម្រាប់ធ្វើអីហ្នឹង? »
មករាឆ្លើយ « សម្រាប់អបអរថ្ងៃចូលឆ្នាំខ្មែរហ្នឹងណា »។
« ចុះស្បៀងធំនោះវិញដាក់អីហ្នឹង? » តែលោកគ្រូសុខមិនឆ្លើយទេ បានត្រឹមញញឹម។
ម្ដាយពួកគេក៏សួរទៅយ៉េក « យ៉េក! ចុះថ្ងៃបុណ្យចូលឆ្នាំខ្មែរនេះប្រុងធ្វើអ្វីដែរ? »
យ៉េកឆ្លើយ « អត់មានគម្រោងថានឹងធ្វើអីផង »។
ម្ដាយពួកគេនិយាយទៀត « អ៊ុំចឹងអ្នកនិងខេទីអាចមកលេងពួកយើងបានហើយសឹមទៅវត្ត
ទាំងអស់គ្នាតែម្ដង »។
យ៉េកក៏ឆ្លើយ « បើអ៊ីចឹងមែនប្រសើរណាស់! អរគុណមីងច្រើនមែនទែន។
ចាំខ្ញុំដឹកអ្នកទាំងអស់គ្នាទៅតែម្ដង »។
ឮដូចនេះ ក្មេងៗក៏ស្រែកហ៊ោដោយក្ដីសប្បាយរីករាយ។



នៅថ្ងៃពុធ រតនានិងមករាជួយម្ដាយពួកគេសម្អាតផ្ទះ ខណៈពេលដែលគាត់នៅរវល់រៀបចំចម្អិនចំណីអាហារ។



រីឯថ្ងៃព្រហស្បតិ៍វិញ យ៉េកនិងខេទីបានជិះរ៉ឺម៉កកង់បីមកដឹកអ្នកទាំងអស់គ្នាទៅផ្សារម្ដងទៀត។ ម្ដងនេះ ពួកគាត់ទិញតែផ្លែឈើប៉ុណ្ណោះ

( យើងត្រូវបង្ហាញផ្លែឈើម្ដងមួយផ្លែៗ )

មានផ្លែម្នាស់ ក្រូច ស្វាយ ល្ហុង ចេកនិងផ្លែខ្នុរ។



យប់នោះ រតនានិងមករាសប្បាយចិត្តខ្លាំងសឹងតែដេកមិនលក់។



ជាចុងក្រោយ ថ្ងៃសុក្រដែលជាថ្ងៃចូលឆ្នាំទីមួយបានមកដល់។ យ៉េកនិងខេទីនាំគ្នាជិះរ៉ឺម៉កកង់បីមកជាមួយគ្នា ឯលោកគ្រូសុខបានដើរមកជួបជុំគ្នានៅផ្ទះរតនានិងមករា។
ខេទីលាន់មាត់ « អូ! តុបតែងបានស្អាតខ្លាំងណាស់ថ្ងៃនេះ »។
លោកគ្រូសុខក៏ប្រាប់យ៉េកនិងខេទី ថាថ្ងៃទីមួយនៃបុណ្យចូលឆ្នាំខ្មែរគេហៅថាថ្ងៃមហាសង្ក្រាន្ត។
« នេះជាថ្ងៃដែលយើងទទួលស្វាគមន៍ទេវតាឆ្នាំថ្មី។
ផ្លែឈើ ទានធូបនិងភ្លើងលំអទាំងនេះជារណ្តាប់សម្រាប់ទទួលទេវតាឆ្នាំថ្មី ដើម្បីឱ្យទ្រង់ប្រោសប្រណីការពារផ្ទះនិងក្រុមគ្រួសារយើង។
បន្ទាប់មក យើងនឹងទៅវត្តដើម្បីប្រគេនចង្ហាន់ជូនលោកសង្ឃផងដែរ »។



នៅលើរ៉ឺម៉កកង់បី មករាបានសួរខេទី « តើអ្នកចេះសំពះថ្វាយបង្គំលោកសង្ឃឬទេ? »
ខេទីប្រាប់ « ខ្ញុំមិនចេះទេ »។
មករាក៏ដាក់ដៃផ្ទឹមគ្នា ហើយលើកដៃសំពះដល់ថ្ងាសឱនចុះឱនឡើងចំនួន៣ដង។
គាត់ប្រាប់ខេទី « នេះហើយជារបៀបសំពះលោកសង្ឃ។ ខ្ញុំទើបរៀនចេះពីសាលាមត្តេយ្យមក! »



ថ្ងៃបន្ទាប់ជាថ្ងៃសៅរ៍ យ៉េកក៏បានមកដឹកអ្នកទាំងអស់គ្នាទៅវត្តម្តងទៀត។ ខេទីសួរលោកគ្រូសុខ ‹‹ ថ្ងៃនេះជាថ្ងៃអ្វី? ›› ‹‹ នេះជាថ្ងៃទីពីរនៃពិធីបុណ្យចូលឆ្នាំដែលឈ្មោះថា វិរៈវ័នបត។ ថ្ងៃនេះជាថ្ងៃដែលយើងរំលឹកដល់ដូនតាយើងដោយប្រគេនចង្ហាន់ដល់លោកសង្ឃនិងឱ្យទានដល់អ្នកក្រខ្សត់ ››។



ក្រោយពីបានប្រគេនចង្ហាន់លោករួចរាល់ហើយ រតនានិងមករាបានទៅអង្គុយកាយខ្សាច់។
ខេទីឆ្ងល់ក៏សួរ « តើអ្នកទាំងពីរកំពុងលេងដីមែនហ្នឹង? »
មករាឆ្លើយវិញ « មិនមែនទេ! យើងកំពុងពូនខ្សាច់ដើម្បីដាក់លើវាលុកចេតិយជា
ភ្នំខ្សាច់នៅទីនេះ។ ដំបូង យើងពូនចេតិយនៅកណ្ដាល ហើយបន្តពូនលើគ្រប់ចេតិយ
ទាំងអស់ពីឆ្វេងទៅស្ដាំ។ យើងធ្វើអ៊ីចឹងគឺដើម្បីបួងសួងដល់ដូនតាយើងនិងសុំឱ្យ
គ្រួសារយើងមានសុខភាពល្អផងដែរ »។



ថ្ងៃអាទិត្យជាថ្ងៃចុងក្រោយនៃពិធីបុណ្យចូលឆ្នាំដែលមានឈ្មោះថា វារៈឡើងស័ក។
នៅវត្ត គេនាំគ្នាយកទឹកទៅស្រង់ព្រះ។
រតនាប្រាប់ខេទី « ធ្វើអ៊ីចឹងគឺយើងលាងបាបដែលយើងបានសាងពីឆ្នាំមុន
ហើយវាក៏នាំសេចក្ដីសុខមកឱ្យយើងនៅឆ្នាំថ្មីនេះផងដែរ »។



ពេលទៅដល់ភូមិវិញ ដល់ពេលគេនាំគ្នាស្រង់ព្រះរស់ម្តង។
រតនានិងមករាក៏បានចូលជួយគេស្រង់ព្រះរស់នឹងគេផងដែរ។
រតនានិយាយ « ខ្ញុំសង្ឃឹមថាលោកតានឹងឱ្យដំបូន្មានល្អៗដល់ខ្ញុំដូចឆ្នាំមុនៗអ៊ីចឹង »។



ក្រោយពេលគេបានស្រង់ព្រះរស់រួចរាល់អស់ហើយនោះ ពួកគេក៏ញ៉ាំបាយជុំគ្នា។
ក្រោយពីញ៉ាំចប់សព្វគ្រប់ហើយនោះ លោកគ្រូសុខក៏បានដើរលបៗទៅក្រៅបាត់...



« តើទាំងអស់គ្នារៀបចំខ្លួនហើយឬនៅ? »
លោកគ្រូសុខនិយាយទាំងដៃមានកាន់ស្បោងខៀវធំមួយ។
« យេ៎! » ពួកក្មេងៗស្រែកហើយរត់ជុំវិញលោកគ្រូសុខ។
មករាស្រែកប្រាប់ឱ្យយ៉េកចូលទៅខាងប្រុស។ រតនាក៏ប្រាប់ឱ្យខេទីចូលជួយខាងស្រី។
យ៉េកឆ្ងល់ក៏សួរ « គេកំពុងធ្វើអីហ្នឹង? »
លោកគ្រូសុខក៏ឆ្លើយ « ដល់ពេលលេងល្បែងប្រជាប្រិយខ្មែរយើងហើយ! »



ដំបូង ពួកគាត់លេងល្បែងចោលឈូង



បោះអង្គុញ



និងស្វាដណ្ដើមស្លឹកឈើសិន។
ក្រុមខាងស្រីស្រែកហ៊ោកញ្ជ្រៀវ ដោយសារក្រុមខាងប្រុសៗចាញ់
ហើយត្រូវច្រៀងនិងរាំជាពិន័យ។



បន្ទាប់មកលោកគ្រូសុខបានប្រាប់ទាំងអស់គ្នាឱ្យអង្គុយជារង្វង់។ ម្នាក់ៗក៏ធ្វើតាមសំដីគាត់ ហើយពួកគេក៏ចាប់ផ្តើមលេងល្បែងលាក់កន្សែង។ ក្មេងៗចូលចិត្តដេញចាប់យ៉េកនិងខេទីណាស់។



« បាទ! ដល់ពេលយើងលេងទាញព្រ័ត្រហើយ! »
« យ៉េ! » ម្នាក់ៗហក់ឡើងឈរ ហើយតម្រង់ជួរ។
« ១ ២ ៣ ចាប់ផ្ដើម! » យ៉េកក៏ចូលជួរជាមួយក្រុមប្រុសៗ។



តែភ្លាមនោះ ក្រុមខាងស្រីៗក៏នាំគ្នាស្រែកតវ៉ា « អយុត្តិធម៌ណាស់! យ៉េកមានកម្លាំងស្មើមនុស្សដប់នាក់ទៅហើយហ្នឹង! » លោកគ្រូសុខក៏ដោះស្រាយ « មិនអីទេៗ! ម្តងនេះ ពីរនាក់ខ្ញុំនិងយ៉េកនឹងទាញជាមួយអ្នកទាំងអស់គ្នាក៏បាន »។
« យ៉េ! » ក្មេងៗនាំគ្នាស្រែកសប្បាយរីករាយ។



យ៉េកក៏លាន់មាត់ « ពិធីបុណ្យចូលឆ្នាំខ្មែរពិតជាសប្បាយពិតមែន!
រីករាយថ្ងៃបុណ្យចូលឆ្នាំថ្មីទាំងអស់គ្នា! »។
ក្មេងៗក៏ស្រែកតប « រីករាយថ្ងៃបុណ្យចូលឆ្នាំថ្មី! »។
ខេទីក៏ស្រែកសួរពីក្រោយ « រៀបចំខ្លួនហើយឬនៅទាំងអស់គ្នា? ១ ២ ៣ ចាប់ផ្តើម! »៕




# សួស្តីឆ្នាំថ្មី

អ្នកនិពន្ធ៖ TukTuk

អ្នកគំនូរ៖ ហ៊ិន ឆវិន

គំនូរជីវចល

ធនធានបង្រៀន